**មជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន (មពអយ)**

**Khmer Youth Education Buddhist Center(YEBC)**

វត្តឧណ្ណាលោម កុដិលេខ៤,សង្កាត់ជ័យជំនះ,ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

Tel: +855-12-31 29 08, 12-68 59 99, 12-83 15 02 , 12-21 01 71

Email: kyso2005@yahoo.com , sophan@cambodianyouth.org http://www.cambodianyouth.org

---

# គម្រោងការធម្មចារិក

## ***អប់រំសីលធម៌ សុជីវធម៌ខ្មែរ តាមពុទ្ធឱវាទដល់ក្រុមយុវវ័យ ដើម្បីអូសទាញអោយក្លាយជាសមាជិកដ៏ល្អរបស់សង្គមជាតិខ្មែរ កែខ្លួនអោយឆ្ងាយអបាយមុខ និងគ្រឿងញៀនគ្រប់ប្រភេទ ៗ***

***<u>រៀបចំកម្មពិធីដោយ:</u>*** *ក្រុមសមណនិស្សិត សិស្សគណព្រះគ្រូ* ***អ៊ឹន ប៉ក់*** *អតីតព្រះវិន័យធរខេត្តសៀមរាប មជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន រួមសហការជាមួយ អង្គការធម្មាធិបតេយ្យសកល នៅវិទ្យាល័យនានា នៃរាជធានីភ្នំពេញ ។*

***អប់រំចាប់ថ្ងៃទី២៥ ខែ វិច្ឆិកា ព.ស ២៥៥១ គ.ស ២០០៧ ដល់ថ្ងៃទី ២៥ ខែវិច្ឆិកា ព.ស ២៥៥២ គ.ស២០០៨***

## ១. ឈ្មោះគម្រោងកម្មវិធី

**គម្រោងការធម្មចារិក "អប់រំសីលធម៌ សុជីវធម៌ដល់សិស្សានុសិស្ស យុវជនខ្មែរ"**

## ២. គោលការណ៍ និង ហេតុផល

ដោយពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជាជាសាសនារបស់រដ្ឋ ហើយកំពុងតែរីកចំរើនជាបណ្តើរៗក្នុងពេលបច្ចុប្បន្ន ក្រោយពីសង្គ្រាមក្នុងស្រុកត្រូវបានស្ងប់រំងាប់ ។ទន្ទឹមនឹងការរីកចំរើនលូតលាស់នេះ ព្រះពុទ្ធសាសនាកំពុងប្រឈមមុខបញ្ហាច្រើនយ៉ាង ដូចជា ខ្វះខាតបណ្ឌិតអ្នកប្រាជ្ញ ខ្វះខាតគម្ពីរក្បួនខ្នាតផ្សេងៗ ដែលជាប្រភពធនធានមនុស្សដ៏សំខាន់ក្នុងការអភិវឌ្ឍន៏សង្គមជាតិ ជាពិសេស ក្រុមយុវជន ដែលជាជន្ទល់ដ៏រឹងមាំ ជាសសរទ្រូងបេះដូងជាតិនិងសាសនា បានកំពុងសប្បាយភ្លើតភ្លើននឹងវត្ថុនិយម បានឃ្លាតឆ្ងាយពីវត្តអារាមខ្វះសីលធមិ ខ្វះទំនួលខុសត្រូវនូវតួនាទីរបស់ខ្លួនឯង ដោយឥទ្ធិពលវប្បធមិ អរិយធមិបរទេស និងការឈឺចុកផ្សាននូវមុខរបួសខាងផ្លូវសតិអារម្មណ៏ពីអតីតកាលគ្របសង្កត់ចិត្តគំនិត ធ្វើអោយមានបញ្ហាសង្គមកើតឡើងមិនអាចគេចវេសបាន ។

ដោយមើលឃើញបញ្ហាទាំងអស់នេះ ទើបធ្វើគម្រោងការនេះឡើង ដើម្បីផ្តល់ឱកាសឱ្យក្មេង យុវជន សិស្ស និស្សិត កុមារា កុមារី ដែលជាកុលបុត្រកុលធីតាខ្មែរ បានចូលមកសិក្សានិងបដិបត្តិតាមគន្លងមាគ៌ាព្រះពុទ្ធសាសនា ឱ្យស្គាល់ពីតំលៃព្រះពុទ្ធសាសនា ដែលជាមតិកធមិដ៏សំខាន់របស់ជាតិខ្មែរ និង ដើម្បីអោយយុវជនទាំងអស់នេះ ក្លាយទៅជាបុគ្គលល្អ មានសីលធមិ មានវិន័យ និងមានការទទួលខុសត្រូវនូវតួនាទីរបស់ខ្លួនឯង ដែលត្រូវជាទំពាំងស្នងឫស្សីនៃទឹកដីជាតិមាតុភូមិខ្មែរ សក្តិសមជាវីរបុរស មហាវីរបុរស មហារដ្ឋបុរស ដឹកនាំសង្គមប្រទេសជាតិខ្មែរឈានទៅរកភាពរីកចំរើនដូចអារ្យប្រទេសនានាក្នុងពិភពលោក និងមានសុខសន្តិភាព ថ្កុំថ្កើងរុងរឿង ដូចសម័យកាលមហានគរនៃយើង ។

## ៣. វត្ថុបំណង

-ដើម្បីអោយពួកយុវជនមានឱកាសចូលមកសិក្សា និងគោរពបដិបត្តិព្រះធម៌ក្នុងព្រះពុទ្ធសាសនា មានសីលធម៌ សុជីវធម៌ល្អ ។

-ដើម្បីហ្វឹកអប់រំពួកយុវជន អោយស្គាល់នូវតំលៃសិល្បៈ ទំនៀមទំលាប់ ប្រពៃណី វប្បធម៌ជាតិរបស់ខ្លួនឱ្យបានច្បាស់លាស់ ។

-ដើម្បីហ្វឹកអប់រំពួកយុវជន អោយមានចរិយាមារយាទល្អប្រពៃ មានវិន័យថ្លៃថ្នូរ មានវិជ្ជាដើរគួទន្ទឹមគ្នានឹងគុណធម៌ ។

-ដើម្បីហ្វឹកអប់រំពួកយុវជន អោយក្លាយទៅជា កូន ដ៏ល្អរបស់ឪពុកម្តាយ ជាសិស្សដ៏ល្អរបស់គ្រូ ជាមិត្តដ៏ល្អរបស់មិត្ត ជាពលរដ្ឋដ៏ល្អរបស់សង្គមជាតិ និង ជាពុទ្ធសាសនិកជនដ៏ល្អរបស់ព្រះពុទ្ធសាសនា ។

-ដើម្បីហ្វឹកអប់រំពួកយុវជន អោយមានស្មារតីភ្ញាក់រលឹក ស្រលាញ់នូវស្ថាប័នជាតិ សាសនា និង ព្រះមហាក្សត្រ ធ្វើខ្លួនអោយឆ្ងាយពីអបាយមុខ គ្រឿងញៀនគ្រប់ប្រភេទ ឈប់បង្កើតបងធំបងតូចវាយតប់កាប់សំលាប់គ្នា ធ្វើខ្លួនឱ្យសក្តិសមជាទំពាំងស្នងឫស្សីរបស់ជាតិ ។

-ដើម្បីអោយពួកយុវជនបានសិក្សាគោលធម៌៥ សីល៥ និង បដិបត្តិ សមាធិ ចំរើនភាវនា ធ្វើកាយ វាចា និងចិត្ត ប្រព្រឹត្តតែសុខបរិសុទ្ធស្អាតស្អំ បន្ទុំគុណធម៌ ឧត្តមគតិស្រស់ផូរផង់ ភ្ញាក់ខ្លួនរលឹកដឹងគុណគោរពមាតាបិតា គ្រូ ព្រឹទ្ធាចារ្យ និង ជាកាតព្វកិច្ចតបគុណដល់បុព្វការីជនដូនតាខ្មែរមហានគរ បណ្តុះគំនិត មនសិការ ស្នេហា ស្រឡាញ់ជាតិមាតុភូមិ វប្បធម៌ អរិយធម៌ខ្មែរ និងកើតការប្រាថ្នាឱ្យ *ប្រជាជនខ្មែរទាំងអស់មានសុវត្ថិភាព សុខភាពល្អ រំដោះខ្លួនចេញផុតពីភាពអត់ឃ្លាន* និងធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាយើងទទួលនូវសុខសន្តិភាព យ៉ាងពិតប្រាកដ ។

-ដើម្បីយុវជនបានរួមចំណែកទទួលខុសត្រូវចំពោះជាតិខ្មែរ អភិវឌ្ឍន៍ជាតិខ្មែរជាមួយរាជរដ្ឋាភិបាល ធ្វើខ្លួនអោយក្លាយជាមហាវីរបុរសដូចបុព្វព្រះមហាវីរក្សត្រខ្មែរ បុព្វមហាវីរបុរសខ្មែរ មហារដ្ឋបុរសខ្មែរ ដូចមាន **សម្តេចព្រះសង្ឃ រាជ ជួន ណាត** និង **សម្តេចព្រះបាទជ័យវរ្ម័នទី៧** ជាដើម និងអ្នកប្រាជ្ញ បញ្ញវន្ត កវី បណ្ឌិត អ្នកស្នេហាជាតិ ដែលបានបូជាព្រះជន្មជីព ពលីជីវិត ដើម្បីការពារសាសនា វប្បធម៌ និងជាតិមាតុភូមិខ្មែរ អោយរីកចំរើនរុងរឿង ឋិតស្ថេរគង់វង់ដល់សព្វថ្ងៃ ។

## ៤. បុគ្គលដែលនឹងចូលមកទទួលការអប់រំ

យុវសិស្សវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ មានវិទ្យាល័យចំនួន ៨ ជាគោលដៅធ្វើការអប់រំ គឺ វិទ្យាល័យស៊ីសុវត្ថិ វិ.ទូលទំពូង,យុគន្ធរ, វិទ្យាល័យសន្ធរម៉ុក វិទ្យាល័យបាក់ទូក វិទ្យាល័យបឹងត្របែក វិទ្យាល័យវត្តភ្នំ និងវិទ្យាល័យវត្តកោះ ដែលមានចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ចំនួនសរុបសិស្សានុសិស្សរួមវិទ្យាល័យទាំងអស់មាន **៤៧,៨៥១**នាក់,សិស្សប្រុសចំនួន **២៦,៦៣៣** នាក់,សិស្សស្រីចំនួន **២១,២១៨** នាក់ ។

## ៥. ទីកន្លែងចូលទៅអប់រំ

សាលារៀនវិទ្យាល័យទាំង ៨ ស្ថិតក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

## ៦. រយៈពេលក្នុងការអប់រំ

រវាងថ្ងៃទី ២៥ ខែ វិច្ឆិកា ព.ស ២៥៥១ គ.ស ២០០៧ ដល់ថ្ងៃទី ២៥ ខែវិច្ឆិកា ព.ស ២៥៥២ គ.ស២០០៨ រួមទាំងអស់ប្រើរយៈពេល ៨ ខែ ក្នុងចន្លោះរវាង ១ឆ្នាំ ។

## ៧. ស្ថាប័នអ្នកទទួលខុសត្រូវ និងអ្នកមានចំណែកចូលរួមឧបត្ថម្ភគាំទ្រ

១-មជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន

២-អង្គការធម្មាធិបតេយ្យសកល

៣-អង្គការមិត្តសំឡាញ់ខ្មែរពិភពលោកតាមបណ្តាញអ៊ិនធឺរណិត

៤-ព្រះមេគណក្រុង មន្ទីរអប់រំយុវជន និងកីឡា មន្ទីរធម្មការ និងសាសនា និង សាលាក្រុងរាជធានីភ្នំពេញ

៥-អាជ្ញាធរមូលដ្ឋាន និង ក្រុមសមត្ថកិច្ចដែលពាក់ពន្ធ័

៦-ក្រុមសមណនិ ស្សិត សិស្សគណព្រះតេជគុណព្រះគ្រូ**អ៊ួន ម៉ក់** សិក្សាក្នុង និង ក្រៅប្រទេស

៧-សប្បុរសជន ពុទ្ធបរិស័ទទូទៅ ទាំងក្នុងនិងក្រៅប្រទេស

## ៨. អ្នកទំនាក់ទំនង និងដំណើរការរៀបចំកម្មវិធីអប់រំ

-សមណសិស្ស និស្សិត ជាបុគ្គលិក នៃមជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន និងអង្គការធម្មាធិបតេយ្យសកល

## ៩. វិធីដំណើរការកម្មវិធីអប់រំ

-ធ្វើលិខិតសុំអនុញ្ញាតពីក្រសួងសមត្ថកិច្ចដែលពាក់ពន្ធ័តាមរយៈអាជ្ញាធរមូលដ្ឋាន

-ប្រកាសឃោសនាតាមទូរទស្សន៍ វិទ្យុ កាសែត អ៊ិនធឺរណិត និង ផ្តល់ពត៌មានដល់សាលារៀន អង្គការ ស្ថាប័ន សមាគម មូលនិធិ និង ពុទ្ធបរិស័ទទាំងក្នុង និង ក្រៅប្រទេស ។

## ១០. កម្មវិធីអប់រំ និង វិធីការបង្រៀន

### ១០.១. ផ្នែកជំនាញការ ឬ ពិធីការ

វិជ្ជា ប្រវត្តិព្រះពុទ្ធសាសនា ពុទ្ធប្បវត្តិ

-វិជ្ជាធម្ម និងជីវិតយុវវ័យសម័យថ្មី មានត្រៃសិក្ខា គោលធម៌នៃសេចក្តីសំរេច គោលធម៌ភាវៈជាអ្នកដឹកនាំ ជាដើម

-វិជ្ជាសីលធម៌ និង ចរិយាធម៌ ( សីល ៥, ធម៌ ៥) និង គោលធម៌យុវជនឆ្នើមប្រាំយ៉ាង

-វិជ្ជា វប្បធម៌ ប្រពៃណីខ្មែរ និង សាសនពិធី ពិធីបុណ្យផ្សេងៗ

-វិជ្ជា និយាយពីគុណព្រះរតនត្រ័យ និងការអភិវឌ្ឍន៍ជីវិតតាមទ្រឹស្តីថ្ងៃប្រសូត្រ ត្រាស់ដឹង បរិនិព្វាន

-វិជ្ជា ព្រះពុទ្ធសាសនា ជាភាសាអង់គ្លេស

### ១០.២. ផ្នែកបដិបត្តិ

-នមស្សការព្រះរតនត្រ័យ សមាទានសីល (៥)

-ហ្វឹកធ្វើសមាធិ ចំរើនភាវនា ដើរចង្ក្រម ផ្សាយមេត្តាធម៌

-ហ្វឹកហាត់ចរិយាមារយាទខ្មែរ គារវកិច្ច ការនិយាយស្តី និង របៀបក្រាបសំពះ ថ្វាយបង្គំ ជាដើម

-ល្បងបញ្ញា បញ្ហាធម្មរីករាយសប្បាយអារម្មណ៍បង្កប់ខ្លឹមសារ សំដែងសេចក្តីក្លាហាន ចោទឆ្លើយសំណួរផ្សេងៗ

### ១០.៣. ផ្នែកសកម្មភាពក្នុងសង្គម

-ហ្វឹកហាត់ការថ្លែងការណ៍ សង្កថា សុន្ទរកថា អធិប្បាយវែកញែក និង វេទិកាអធិប្បាយជាក្រុម

-ហ្វឹកហាត់ឱ្យចេះបង្កើតគំនិតនិងបញ្ញាច្នៃប្រឌិតទស្សនៈថ្មីៗ និងចេះដោះស្រាយជំលោះផ្សេងៗ

-ផ្លាស់ប្តូរយោបល់រវាងអ្នកចូលដែលអប់រំ និង គណៈគ្រូធម្មាចារ្យអ្នកផ្តល់ការអប់រំ

-ហ្វឹកហាត់បណ្តុះគំនិតស្រឡាញ់ជាតិ មានទំនួលខុសត្រូវចំពោះស្ថាប័នជាតិ សាសនា និង ព្រះមហាក្សត្រ

-ហ្វឹកហាត់អោយចេះស្រឡាញ់នូវវប្បធម៌ អរិយធម៌ ប្រពៃណី រហូតដល់សង្គមបរិដ្ឋាននៅជុំវិញខ្លួន

១០.៤. ផ្នែកសកម្មភាពអត្ថាធិប្បាយពិសេស

*-ទាទីធម្មសង្វេគ "អត្ថាធិប្បាយពិសេស ស្តីអំពីគុណទឹកដោះម្តាយ "*

## ១១. វាគ្មិនពិសេស និងគ្រូធម្មាចារ្យផ្តល់ការអប់រំដល់អ្នកចូលមកអប់រំ

១. វាគ្មិនពិសេសដែលមកផ្តល់ចំណេះដឹង

-ព្រះរាជាគណៈ ព្រះមេគណ ព្រះអនុគណ និងព្រះសង្ឃដែលមានការសិក្សា និងបទពិសោធន៍ខ្ពស់

-អភិបាលក្រុង អភិបាលខ័ណ្ឌ ប្រធានមន្ទីរធម្មការ និង សាសនាក្រុង-ខ័ណ្ឌ និងអ្នកមានវាទសិល្បៈល្បីៗ

-អ្នកមុខ អ្នកការ ភ្ញៀវកិត្តិយសទូទៅ អង្គការ និង សមាគមផ្សេងៗ ជាដើម

២. គ្រូធម្មាចារ្យ ផ្តល់ការអប់រំប្រចាំគម្រោង

-ក្រុមសមណសិស្ស និស្សិតខ្មែរ និង ព្រះសង្ឃ ដូនជី ដែលមានការសិក្សា ចំណេះដឹង និងបទពិសោធន៍ខ្ពស់

## ១២. គណៈកម្មការ និងបុគ្គលសំខាន់ៗក្នុងគម្រោងកម្មវិធីអប់រំ

**១២.១-**គណៈកម្មការឧត្តមទីប្រឹក្សា និងឧបត្ថម្ភគម្រោងកម្មវិធីអប់រំ

| | |
|---|---|
| ១-ព្រះបណ្ឌិតធម្មាចារ្យ **ហុក សាវណ្ណា** | ២-ព្រះគ្រូវិបស្សនាចារ្យ **កែង ហុង** |
| ៣- ភិក្ខុ វោទានោ **សេង សុគំណ** | ៤-ឯកឧត្តមបណ្ឌិត **គុល ផេង** |
| ៥-ឯកឧត្តមបណ្ឌិត **ប៉ក់ ថាវិន** | ៦-លោកគ្រូ **ហូ គិមឡុង** |

១២.២- គណៈកម្មការ និងគ្រូធម្មាចារ្យ រៀបចំគម្រោងកម្មវិធីអប់រំ

| | | |
|---|---|---|
| ១-ភិក្ខុ វ៉ាត់ វិបុល | ប្រធានគម្រោងកម្មវិធី | បរិញ្ញាប័ត្រទស្សនវិជ្ជា |
| ២-ភិក្ខុ ផាន់ ចន្ទកុណា | អនុ.ផ្នែកទំនាក់ទំនងទូទៅ | បរិញ្ញាប័ត្រគ្រប់គ្រង |
| ៣-ភិក្ខុ មហាថៃ ជួប | អនុ.ផ្នែកអប់រំ | សមណនិស្សិតសាកលវិទ្យាល័យព្រះសីហនុរាជ-ធនធានមនុស្ស |
| ៤-ភិក្ខុ ឌី ថេហួយ៉ា | អនុ.ផ្នែកសម្របសម្រួល និងផ្សព្វផ្សាយ | សមណនិស្សិតត្រៀមអនុបណ្ឌិតសាកលវិទ្យាល័យបញ្ញាសាស្រ្ត |
| ៥-ភិក្ខុ ហ៊ា គីមសាន | លេខាធិការ | សមណនិស្សិតបរិញ្ញាប័ត្រសេដ្ឋកិច្ច ក្រុងប៉ាងកក |
| ៦-ភិក្ខុមហា ដោក ដុំ | ហិរញ្ញិក | សមណនិស្សិតពុទ្ធិក សាកលវិទ្យាល័យព្រះសីហនុរាជ |
| ៧-ភិក្ខុមហា សេត សែត | ធម្មាចារ្យ ឬគ្រូបង្រៀន | សមណនិស្សិតពុទ្ធិក សាកលវិទ្យាល័យព្រះសីហនុរាជ |
| ៨-ភិក្ខុមហា ហឹ សទ្ធា | ធម្មាចារ្យ ឬគ្រូបង្រៀន | សមណនិស្សិតពុទ្ធិក សាកលវិទ្យាល័យព្រះសីហនុរាជ |
| ៩- ភិក្ខុ ឈឿង វង្សវិសុទ្ធ | ធម្មាចារ្យឬគ្រូបង្រៀន | សមណនិស្សិត ពុទ្ធិក សាកលវិទ្យាល័យ សម្តេចប៊ូគ្រី |

| | | |
|---|---|---|
| ១០- ភិក្ខុ សុខ សារេតា | ធម្មាចារ្យឬគ្រូបង្រៀន | សមណសិស្សពុទ្ធិកវិទ្យាល័យវត្តព្រះរាជបូណ៌ |
| ១១- ភិក្ខុ ផាត គឹមសួរ | ធម្មាចារ្យឬគ្រូបង្រៀន | សមណសិស្សពុទ្ធិក វិទ្យាល័យវត្តព្រះរាជបូណ៌ |
| ១២-ភិក្ខុ អៀម បុនធឿន | ធម្មាចារ្យឬគ្រូបង្រៀន | សមណនិស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រ |
| ១៣- ដូនជី នៅ ចាន់ចំណាន | ធម្មាចារ្យឬគ្រូបង្រៀន | គ្រូវិបស្សនាវត្តនន្ទមុនី |
| ១៤- ដូនជី កេត សុវណ្ណនី | ធម្មាចារ្យឬគ្រូបង្រៀន | គ្រូវិបស្សនាវត្តនន្ទមុនី |
| ១៥- លោក ស៊ាង សុខអាន | ជំនួយការហិរញ្ញិក | និស្សិតសាកលវិទ្យាល័យបឹងត្របែក |

## ១៣. ថវិកា ឬបច្ច័យដែលនឹងត្រូវចំណាយប្រើប្រាស់លើកម្មវិធីអប់រំ

| | |
|---|---|
| -ចំណាយទៅលើសោហ៊ុយធ្វើដំណើរទំនាក់ទំនងច្បាប់ផ្សេងៗ | ចំនួន ២.០០០,០០០៛ |
| -ចំណាយទៅលើឧបករណ៍សិក្សា ប៉ាកកា សៀវភៅ ខ្មៅដៃ | ចំនួន ២០,០០០,០០០៛ |
| -ចំណាយទៅលើ សម្ភារៈ ឯកសារ សំរាប់បង្រៀន និងចែកឱ្យសិស្ស | ចំនួន ២៣,០០០,០០០៛ |
| -ចំណាយទៅលើថ្លៃចង្ហាន់ព្រឹក-ថ្ងៃត្រង់ ១ថ្ងៃ ៦០,០០០៛ រយៈ១ឆ្នាំ | ចំនួន ៧,០០០,០០០៛ |
| -ចំណាយទៅលើទឹកសុទ្ធ ទឹកភេសជ្ជៈ ១ថ្ងៃ ៣០,០០០ ៛ រយៈ១ឆ្នាំ | ចំនួន ៤,០០០,០០០៛ |
| -ចំណាយទៅលើយានជំនិះសំរាប់ធម្មាចារ្យ ចំនួន១៥ រូប | ចំនួន ២០.០០០,០០០ ៛ |
| -ចំណាយទៅលើទិញហ្វីល ផ្តិតរូប កាត់តវីដេអូ | ចំនួន ២.០០០,០០០ ៛ |
| -ចំណាយទៅលើជួលកន្លែង រោង គ្រឿងសម្លេង ភ្លើង | ចំនួន ១៥.០០០.០០០៛ |
| -ចំណាយទៅលើការឃោសនាពតិមានផ្សេងៗ តាមវិទ្យុ ទូរទស្សន៍ | ចំនួន ២.០០០,០០០ ៛ |
| -ចំណាយទៅលើថ្នាំរក្សាព្យាបាលរោគ | ចំនួន ១.០០០,០០០ ៛ |
| -ចំណាយទៅលើសក្ខីប័ត្រ ប័ណ្ណសរសើរ និងវិញ្ញាប័ណ្ណប័ត្រសិស្ស | ចំនួន៤៥.០០០,០០០ ៛ |
| -ចំណាយផ្សេងៗ | ចំនួន ២,០០០,០០០ ៛ |

**សរុបទាំងអស់ ចំនួន ១៤៤,០០០,០០០ ៛**

## ១៤. ប្រភពថវិកា(បច្ច័យ)នឹងទទួលបាន

-សម្តេច ទ្រង់ អ្នកអង្គម្ចាស់ លោកឧកញ៉ា ឯកឧត្តម លោកជំទាវ និង ញាតិញោម ពុទ្ធបរិស័ទ សប្បុរសជនទូទៅ ទាំងក្នុង និង ក្រៅប្រទេស ។

-អង្គការ ស្ថាប័ន មូលនិធិ និង ក្រុមហ៊ុនផ្សេងៗ ក្នុង និង ក្រៅប្រទេស

## ១៥. លទ្ធផលដែលនឹងអាចទទួលបានក្រោយពីការបោះជំរុំអប់រំ

-ធ្វើអោយយុវជនខ្មែរយល់នូវគោលធម៌ព្រះពុទ្ធសាសនា ហើយអាចយកទៅបដិបត្តិពិតក្នុងជីវិតប្រចាំថ្ងៃបាន។

-ធ្វើអោយយុវជនខ្មែរមានការភ្ញាក់រលឹកចេះស្រឡាញ់ស្ថាប័នជាតិ សាសនា និង ព្រះមហាក្សត្រកាន់តែខ្លាំង ។

-ធ្វើអោយយុវជនខ្មែរមានការផ្លាស់ប្តូរអាកប្បកិរិយា ការប្រព្រឹត្ត ក្លាហានគិត ក្លាហានធ្វើតាមផ្លូវល្អត្រឹមត្រូវ យកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ អភិវឌ្ឍន៍ខ្លួនឯងកាន់តែល្អប្រសើរឡើង មានការព្យាយាម អត់ធន់ រឹងប៉ឹងអាចដោះស្រាយបញ្ហា ឧបសគ្គចំពោះមុខបានយ៉ាងជោគជ័យ និង ត្រឹមត្រូវដោយសមត្ថភាពខ្លួនឯង ។

-ធ្វើអោយមានមារយាទល្អ ចេះស្រឡាញ់ជីវិតខ្លួន ជីវិតអ្នកដទៃ ចេះស្រឡាញ់បរិស្ថានសង្គម បរិស្ថានធម្មជាតិ វប្បធម៌ អរិយធម៌ ទំនៀមទំលាប់ប្រពៃណីខ្មែរយើង រួមគ្នាថែរក្សាអោយបានគង់វង្សតរៀងទៅ ។

-ប្រព្រឹត្តខ្លួនបានល្អ ក្លាយជាកូនដ៏ល្អ ជាសិស្សដ៏ល្អ ជាមិត្តដ៏ល្អ ជាពលរដ្ឋដ៏ល្អ និងជាពុទ្ធសាសនិកជនដ៏ល្អ មានទស្សនៈវិស័យទូលំទូលាយក្នុងការទទួលខុសត្រូវនូវតួនាទីជាយុវជនខ្មែរ ដែលត្រូវស្នងវង្សត្រកូលប្រទេសជាតិទៅថ្ងៃអនាគត ធ្វើតែប្រយោជន៍សុខដល់ខ្លួនឯង ដល់អ្នកដទៃ និង ដល់សង្គមប្រទេសជាតិទាំងមូល ។

***៦អាសយដ្ឋានទំនាក់ទំនង:*** ***វត្តឧណ្ណាលោម ក្រុងលេខ៤,សង្កាត់ជ័យជំនះ,ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា***

☞ ព្រះតេជគុណ **សេង សុភ័ណ** ប្រធានទីប្រឹក្សាប្រចាំគម្រោង គង់នៅប្រទេសកាណាដា *ទូរស័ព្ទ:១(៤០៣)២៣៥ ៥៤១៥*
Email: sophan@cambodianyouth.org

☞ ភិក្ខុ **ទ៉ាត់ ទិបុល** ប្រធានគម្រោង ទូរស័ព្ទ :(៨៥៥)១២ ៣១២-៥០៨,០១១-៥៦៨-១០១,០៩៨-៦២៨-១៧៣
*Email:* ***kyso2005@yahoo.com http://www.cambodianyouth.org***

☞ ភិក្ខុ **ផាន់ ចន្ទន៍ករុណា** ទូរស័ព្ទ :(៨៥៥)១២ ៦៨៥-៩៩៩,០១១-៩៦៨-៩៩៩

| | | |
|---|---|---|
| ☞ ភិក្ខុ មហាថៃ ជួប | វត្តមហាមន្ត្រី | ទូរស័ព្ទ :(៨៥៥) ១២-៨៣១-៥០២ |
| ☞ ភិក្ខុ ឌី ថេហ្វយ៉ា | វត្តមហាមន្ត្រី | ទូរស័ព្ទ :(៨៥៥) ១២-២១០-១៧១ |
| ☞ ភិក្ខុ មហា ដោក ជុំ | វត្តបទុមវតី | ទូរស័ព្ទ :(៨៥៥) ១២-៩១៣-៧២៤ |
| ☞ដូនជី នៅ ចាន់ចំណាន | វត្តនន្ទមុនី | ទូរស័ព្ទ :(៨៥៥) ៩២-៩២២-៨៣២ |

*សូមអរព្រះគុណ និងសូមអរគុណ!*